**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ព្រឹទ្ធសភា**
**អគ្គលេខាធិការដ្ឋាន**

# របាយការណ៍
# ស្តីពី
# លទ្ធផលការងាររបស់អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ប្រចាំខែឧសភា និងទិសដៅការងារខែមិថុនា ឆ្នាំ២០១៦

**សេចក្តីផ្តើម** :

នៅក្នុងខែឧសភានេះ អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា បានខិតខំបំពេញការងារយ៉ាងសកម្ម និងមមាញឹកលើគ្រប់ការដ្ឋាន ដើម្បីផ្តល់សេវាជូនថ្នាក់ដឹកនាំ សមាជិក-សមាជិកាព្រឹទ្ធសភា ក្នុងការអនុវត្តមុខងាររបស់ខ្លួនបានល្អប្រសើរតាមរយៈលទ្ធផលសំខាន់ៗដូចខាងក្រោមនេះៈ

## I.លទ្ធផលការងាររបស់អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា:

### ១.មុខងារនីតិកម្ម:

| *របនាសម្ព័ន្ធនយោបាយ* | *របនាសម្ព័ន្ធរដ្ឋបាល* |
|---|---|
| - ប្រជុំគណៈកម្មការពិសេសចំនួន០២លើក ដើម្បីពិនិត្យពិភាក្សាលើសេចក្តីស្នើច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា និងសេចក្តីព្រាងក្រមសីលធម៌សមាជិកព្រឹទ្ធសភា ។ | - បានផ្គត់ផ្គង់សម្ភារៈ ភេសជ្ជៈ និងអាហារសម្រន់សម្រាប់ប្រជុំគណៈកម្មការពិសេសចំនួន០២លើក មានអ្នកចូលរួមចំនួន៥០នាក់<br>- ថតចម្លងឯកសារបានចំនួន០៧សំណើ អស់ក្រដាសចំនួន១៦,២១៤សន្លឹក និងធ្វើជាសៀវភៅចំនួន៤០ក្បាល អស់ក្រដាសចំនួន១៩,៦៤០សន្លឹក<br>- បានប្រើប្រាស់កម្លាំងសន្តិសុខផ្ទៃក្នុង០២លើក ចំនួន២៥នាក់ ដើម្បីការពារសន្តិសុខ សុវត្ថិភាព សណ្តាប់ធ្នាប់ក្នុងកិច្ចប្រជុំផ្សេងៗ<br>- ប្រជុំក្រុមការងារបច្ចេកទេស ដើម្បីពិនិត្យសិក្សាស្រាវជ្រាវ និងរៀបចំសេចក្តីព្រាងសេចក្តីស្នើបទបញ្ញាផ្ទៃក្នុងព្រឹទ្ធសភា និងសេចក្តីព្រាងក្រមសីលធម៌សមាជិកព្រឹទ្ធសភា<br>- បានទទួលសេចក្តីព្រាងច្បាប់ចំនួន០២ច្បាប់ |



វិមានរដ្ឋចំការមន មហាវិថីព្រះនរោត្តម រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
ទូរស័ព្ទ: (855 23) 211 441, 211 442, 211 443 ទូរសារ: (855 23) 211 446, E-mail: oum_sarith@camnet.com.kh

| | |
|---|---|
| | ពីរាជរដ្ឋាភិបាល និងបានចាត់ចែងតាមនីតិវិធី<br>- បន្តធ្វើបច្ចុប្បន្នភាពបញ្ជីច្បាប់ដែលព្រឹទ្ធសភាបានពិនិត្យ និងឲ្យយោបល់តាមឆ្នាំ និងនីតិកាល<br>- បាននឹងកំពុងបន្តសិក្សាស្រាវជ្រាវ និងរៀបចំឯកសារជំនួយស្មារតីសេចក្តីព្រាងច្បាប់ចំនួន០៣ច្បាប់ និងស្រាវជ្រាវលើប្រធានបទសំខាន់ៗពាក់ព័ន្ធនឹងតម្រូវការចាំបាច់របស់ស្ថាប័នចំនួន០៤ប្រធានបទ<br>- បានត្រួតពិនិត្យប្រព័ន្ធសំឡេងម៉ៃក្រូហ្វូន កាមេរ៉ាវីដេអូសុវត្ថិភាព ចំនួន៨៩លើក ថត និងផ្សព្វផ្សាយព័ត៌មានចំនួន៧៩លើក បង្ហោះលើគេហទំព័រព្រឹទ្ធសភា និងផលិតជា Video Online ចំនួន១៦លើក ។ |

**២.មុខងារតំណាង** :

| របនាសម្ព័ន្ធនយោបាយ | របនាសម្ព័ន្ធរដ្ឋបាល |
|---|---|
| - សកម្មភាពការងាររបស់ថ្នាក់ដឹកនាំ និងសមាជិកព្រឹទ្ធសភាបាន៖<br>+អញ្ជើញថ្វាយព្រះពរព្រះករុណាព្រះបាទ **សម្តេចព្រះបរមនាថ នរោត្តម សីហមុនី** ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ក្នុងព្រះរាជពិធីបុណ្យចម្រើនព្រះជន្មវស្សាគម្រប់៦៣ព្រះវស្សា យាងចូល៦៤ព្រះវស្សា នៅព្រះបរមរាជវាំង<br>+អញ្ជើញចូលរួមជាកិត្តិយសក្នុងព្រះរាជពិធីច្រត់ព្រះនង្គ័ល ក្រោមព្រះរាជអធិបតីដ៏ខ្ពង់ខ្ពស់បំផុតព្រះករុណាព្រះបាទ **សម្តេចព្រះបរមនាថ នរោត្តម សីហមុនី** ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា | - រៀបចំពិធីជូនថ្នាក់ដឹកនាំ សមាជិកព្រឹទ្ធសភាអញ្ជើញចុះមូលដ្ឋាន និងជាអធិបតីភាព ក្នុងពិធីផ្សេងៗចំនួន២៣លើក<br>- បានចុះបេសកកម្មសហការជាមួយក្រុមបច្ចេកទេសរបស់ក្រុមហ៊ុន ម៉ុង ឫទ្ធី ពិនិត្យស្ថានភាពជាក់ស្តែងដើម្បីជីក និងស្តារស្រះ នៅខេត្តកំពត<br>- បានធ្វើកំណត់បង្ហាញ និងបញ្ជូនពាក្យបណ្តឹងចេញទៅក្រសួង ខេត្ត និងស្ថាប័នពាក់ព័ន្ធ<br>- បានផ្តល់សេវារដ្ឋបាល ពិធីការ និងទំនាក់ទំនងក្នុងដំណើរការរៀបចំកិច្ចប្រជុំ ការចុះស្រាវជ្រាវប្រមូលព័ត៌មាន ពិភាក្សាការងារ ការរៀបចំវេទិកា ការចុះតាមដានស្វែងយល់លទ្ធផលក្រោយការរៀបចំវេទិកា |

| | |
|---|---|
| នៅទីលានជល់ដំរី ខេត្តសៀមរាប<br>+អញ្ជើញចូលរួមជាកិត្តិយស និងជាអធិបតីភាពដ៏ខ្ពង់ខ្ពស់ ក្នុងពិធីអបអរសាទរខួបលើកទី១៥៣ ទិវាពិភពលោកកាកបាទក្រហម អឌ្ឍចន្ទក្រហម០៨ ឧសភា ២០១៦ ក្រោមប្រធានបទ "កាកបាទក្រហមកម្ពុជាមានគ្រប់ទីកន្លែងសម្រាប់គ្រប់ៗគ្នា"<br>+ អញ្ជើញនាំយកបច្ច័យ ទេយ្យវត្ថុ អង្ករ គ្រឿងឧបភោគ បរិភោគ ទៅប្រគេនព្រះសង្ឃមហាសុមេធាធិបតី នន្ទ ង៉ែត សម្តេចព្រះសង្ឃនាយក និងជាព្រះចៅអធិការវត្តបទុមវតី និងចុះពិនិត្យផ្ទាល់ដល់កន្លែងដឹកជញ្ជូនចែកចាយទឹកជូនប្រជាពលរដ្ឋនៅខណ្ឌព្រែកព្នៅ ព្រមទាំងចុះជួបសំណេះសំណាលជាមួយប្រជាពលរដ្ឋ និងសាកសួរសុខទុក្ខ និងជូនពរ ឯកឧត្តមយុន ឈី អតីតរដ្ឋមន្ត្រីក្រសួងគមនាគមន៍ ដឹកជញ្ជូន និងប្រៃសណីយ៍ ក្នុងឱកាសដែលឯកឧត្តមមានជន្មាយុ៧៩ ឈានចូល៨០ឆ្នាំ និងចូលរួមរំលែកមរណៈទុក្ខក្រុមគ្រួសារសព ឯកឧត្តម ឧត្តមសេនីយ៍ឯក ទៀ សុទ្ធ នៅរាជធានីភ្នំពេញ<br>+អញ្ជើញចុះសួរសុខទុក្ខ សំណេះសំណាលជាមួយអាជ្ញាធរ ប្រជាពលរដ្ឋ ដឹកនាំក្រុមគ្រូពេទ្យស្ម័គ្រចិត្តទៅពិនិត្យ និងព្យាបាលជំងឺ ពិនិត្យស្ថានភាពជីវភាពរស់នៅប្រចាំថ្ងៃ និងការប្រកបអាជីវកម្ម | និងកម្មវិធីផ្សេងៗ<br>- បានធ្វើបច្ចុប្បន្នភាពក្រុមប្រឹក្សាក្រុង ស្រុក ឃុំ សង្កាត់ (ខេត្តតាកែវ កំពត កែប កំពង់ចាម ត្បូងឃ្មុំ បាត់ដំបង និងខេត្តព្រះសីហនុ)<br>- បានរៀបចំទីកន្លែងសម្រាប់វគ្គបណ្តុះបណ្តាល សិក្ខាសាលា បទបង្ហាញ និងកិច្ចប្រជុំផ្សេងៗ ចំនួន១២លើក<br>- សហការរៀបចំទីកន្លែងសម្រាប់វេទិកាចំនួន០២លើក នៅខេត្តកំពត និងខេត្តព្រះសីហនុ មានអ្នកចូលរួមសរុបចំនួន១៧០នាក់<br>- បានចុះស្រាវជ្រាវប្រមូលព័ត៌មានជូនក្រុមសមាជិកព្រឹទ្ធសភាភូមិភាគទី២ នៅខេត្តកំពង់ចាម និងបានប្រជុំជាមួយសម្ព័ន្ធភាពជាតិក្រុមប្រឹក្សាថ្នាក់មូលដ្ឋាន ដើម្បីពិភាក្សាអំពីការគាំទ្រថវិកាសម្រាប់វេទិការបស់ក្រុមសមាជិកព្រឹទ្ធសភាប្រចាំភូមិភាគទី៤ នៅខេត្តបន្ទាយមានជ័យ និងតាមបណ្តាក្រុងស្រុកចំនួន០៧លើក<br>- ធ្វើលិខិតបេសកកម្មជូនសមាជិក-សមាជិកា និងមន្ត្រីរាជការព្រឹទ្ធសភាចំនួន២៤៩នាក់ ស្មើនឹង៦២ច្បាប់ និងលិខិតអនុញ្ញាតច្បាប់ជូនសមាជិកព្រឹទ្ធសភាចំនួន១០នាក់ ស្មើនឹង១០ច្បាប់<br>- ថតចម្លងឯកសារចំនួន១៧សំណើ អស់ក្រដាសចំនួន៨,១៣៨សន្លឹក និងធ្វើជាសៀវភៅចំនួន០២ក្បាល អស់ក្រដាសចំនួន៧៤០សន្លឹក<br>- ផ្តល់សេវាដឹកជញ្ជូន និងថវិកាសម្រាប់ថ្នាក់ដឹកនាំសមាជិក-សមាជិកា និងមន្ត្រីរាជការព្រឹទ្ធសភាចុះទៅតាមបណ្តាខេត្តទាំង៨ភូមិភាគ ចំនួន១០៤នាក់ |

| | |
|---|---|
| លក់ដូរ ពិនិត្យការស្តារប្រឡាយ និងការជួសជុលផ្លូវអមប្រឡាយ នៅខេត្តកណ្តាល ខេត្តសៀមរាប ខេត្តកំពត ខេត្តតាកែវ ខេត្តត្បូងឃ្មុំ ខេត្តកំពង់ចាម ខេត្តព្រៃវែង ខេត្តស្វាយរៀង និងខេត្តបន្ទាយមានជ័យ<br>+ អញ្ជើញជាអធិបតីក្នុងកិច្ចប្រជុំផ្ទៃក្នុងក្រុមភូមិភាគទី៥ ដើម្បីត្រៀមរៀបចំវេទិកាភូមិភាគទី៥ ស្តីពីសេវាសាធារណៈ ផ្តោតសំខាន់ការផ្គត់ផ្គង់ទឹកប្រើប្រាស់សម្រាប់ប្រជាពលរដ្ឋ ការធ្វើអត្តសញ្ញាណប័ណ្ណ និងភូមិ-ឃុំមានសុវត្ថិភាព<br>+អញ្ជើញជាអធិបតីក្នុងពិធីសម្ពោធដាក់ឲ្យប្រើប្រាស់សាលប្រជុំវរៈសេនាតូចការពារព្រំដែនគោក៧០១ ដឹកនាំក្រុមគ្រូពេទ្យស្ម័គ្រចិត្តពិនិត្យ និងព្យាបាលជំងឺ និងនាំយកទឹកស្អាត ម៉ូទ័រ និងទុយោទឹក ចែកជូនសាលាបឋមសិក្សាអូរសោម និងប្រជាពលរដ្ឋ ដែលខ្វះទឹកប្រើប្រាស់ ព្រមទាំងពិនិត្យដំណើរការសាងសង់ទំនប់វារីអគ្គិសនីសេសានក្រោមពីរ នៅខេត្តស្ទឹងត្រែង<br>+អញ្ជើញចូលរួមក្រុងពាលី និងពិធីនិមន្តព្រះពុទ្ធបដិមាអង្គធំកសាងពីថ្មភក់តម្កល់បល្ល័ង្កព្រះវិហារវត្តហ្វាំង នៅខេត្តរតនគិរី<br>- បានធ្វើបទបង្ហាញ ស្តីពីតួនាទី ភារកិច្ចរបស់ព្រឹទ្ធសភា ជូនសាស្ត្រាចារ្យ សិស្ស និងនិស្សិតមកពីសាកលវិទ្យាល័យ | ស្មើនឹង២១លើក<br>- ទទួលលិខិតចូលចំនួន៦៩០ច្បាប់ និងបញ្ជូនលិខិតចេញចំនួន៥៥៤ច្បាប់<br>- បានរៀបចំពិព័រណ៍សៀវភៅ និងអភិវឌ្ឍន៍ទម្លាប់នៃការអាននៅបណ្ណាល័យព្រឹទ្ធសភា ដោយសហការជាមួយវិទ្យាស្ថានខុងជឺ និងបានរៀបចំពិព័រណ៍រូបភាព១៦៥សន្លឹក នៅមុខអគារក្រហម និងខាងមុខខ្លោងទ្វារធំព្រឹទ្ធសភាចំនួន០៣លើក<br>- ផ្តល់សៀវភៅជូនមន្ទីរទំនាក់ទំនងរដ្ឋសភា-ព្រឹទ្ធសភា និងអធិការកិច្ចខេត្តប៉ៃលិន ខេត្តសៀមរាប និងសាកលវិទ្យាល័យភ្នំពេញអន្តរជាតិចំនួន៤៩៧ក្បាល<br>- ផ្តល់រូបថតចំនួន១៥០សន្លឹក និងឯកសារព្រឹត្តិបត្រ-អត្ថបទសារព័ត៌មានចំនួន៣៥អត្ថបទ<br>- ទទួលមន្ត្រីរាជការ សិស្សនិស្សិត និងសាធារណជនចូលអានសៀវភៅចំនួន១៧៨នាក់ ធ្វើប័ណ្ណសមាជិក០៤នាក់ ខ្ចីសៀវភៅចំនួន៥៨ក្បាល និងសងវិញចំនួន៤៩ក្បាល<br>- សម្របសម្រួលទទួលដំណើរទស្សនកិច្ចសិក្សាចំនួន០៣លើក របស់សិស្ស-និស្សិតនៃសាកលវិទ្យាល័យអាស៊ី-អឺរ៉ុប វិទ្យាស្ថានអភិវឌ្ឍន៍និស្សិត និងសាលារៀនអន្តរទ្វីបអាមេរិកកាំងសរុបចំនួន ៤១០នាក់<br>- ទទួលឯកសារសៀវភៅពីអង្គការ ស្ថានទូត ស្ថាប័នក្រសួង គ្រឹះស្ថានអប់រំ សប្បុរសជន និងអង្គភាពចំណុះអគ្គលេខាធិការដ្ឋានព្រឹទ្ធសភាចំនួន១៦៥ក្បាល ព្រឹត្តិបត្រចំនួន៤៨ក្បាល ទស្សនាវដ្តីចំនួន២៨ក្បាល រាជកិច្ចចំនួន៨២ក្បាល រាជក្រមចំនួន០៤ និងផែនទីចំនួន០១ ។ |

| | |
|---|---|
| អាស៊ី-អឺរ៉ុប វិទ្យាស្ថានអភិវឌ្ឍន៍និស្សិត និងសាលារៀនអន្តរទ្វីបអាមេរិកកាំង ចំនួន២១០នាក់<br>- ព្រឹទ្ធសភាបានទទួលពាក្យបណ្តឹងចំនួន ០៤ករណី ធ្វើលិខិតអន្តរាគមន៍ទៅស្ថាប័នមានសមត្ថកិច្ចដោះស្រាយចំនួន១១ករណី ធ្វើកំណត់បង្ហាញពាក្យបណ្តឹងចំនួន ១១ករណី ទទួលពាក្យបណ្តឹងជូនជ្រាប ចំនួន១១ករណី ទទួលលិខិតឆ្លើយតប ពីការដោះស្រាយពាក្យបណ្តឹងពីស្ថាប័ន មានសមត្ថកិច្ចចំនួន០៥ករណី និងឆ្លើយ តបទៅម្ចាស់បណ្តឹងអំពីចំណាត់ការ របស់គណៈកម្មការបានចំនួន១២នាក់<br>- ព្រឹទ្ធសភាបានទទួលលិខិតពីរដ្ឋសភា ចំនួន៥៦ច្បាប់ ព្រមទាំងទទួលឯកសារ ពីក្រសួង-ស្ថាប័នពាក់ព័ន្ធ ដែលមាន ឈ្មោះរបស់សមាជិក-សមាជិកាព្រឹទ្ធសភា ចំនួន២៨០ច្បាប់ និងថ្នាក់ដឹកនាំបាន ចុះហត្ថលេខាលើឯកសារផ្សេងៗចំនួន ១៥៧ច្បាប់<br>- ក្រុមសមាជិកព្រឹទ្ធសភាប្រចាំភូមិភាគទី៥ បានរៀបចំវេទិកាថ្នាក់ខេត្ត ស្តីពីសេវា សាធារណៈ ផ្តោតសំខាន់ការផ្គត់ផ្គង់ ទឹកប្រើប្រាស់សម្រាប់ប្រជាពលរដ្ឋ ការធ្វើអត្តសញ្ញាណប័ណ្ណ និងភូមិ- ឃុំ មានសុវត្ថិភាព នៅខេត្តកំពត<br>- ក្រុមសមាជិកព្រឹទ្ធសភាប្រចាំភូមិភាគទី៧ | |

| | |
|---|---|
| បានរៀបចំវេទិកាថ្នាក់ស្រុក ស្តីពីការលើកកម្ពស់សេវាសាធារណៈ និងភូមិ-ឃុំមានសុវត្ថិភាព នៅខេត្តព្រះសីហនុ ។ | |

**៣.មុខងារតាមដានការអនុវត្តច្បាប់/មុខងារព័ត៌មាន:**

| របនាសម្ព័ន្ធនយោបាយ | របនាសម្ព័ន្ធរដ្ឋបាល |
|---|---|
| - សមាជិក សមាជិកាព្រឹទ្ធសភាបានៈ<br>+ អញ្ជើញចុះទៅសិក្សាស្វែងយល់អំពីការអនុវត្តច្បាប់ស្តីពីការបង្ការ និងប្រយុទ្ធទប់ស្កាត់ការរីករាលដាលមេរោគអេដស៍-ជំងឺអេដស៍ ច្បាប់ស្តីពីការគ្រប់គ្រងឱសថ និងការគ្រប់គ្រងលើការប្រកបវិជ្ជាជីវៈឯកជនក្នុងវិស័យវេជ្ជសាស្ត្រ អមវេជ្ជសាស្ត្រ និងជំនួយវេជ្ជសាស្ត្រនៅរាជធានីភ្នំពេញ ខេត្តកណ្តាល និងខេត្តតាកែវ<br>+ អញ្ជើញចុះបេសកកម្មស្វែងរកព័ត៌មានពាក់ព័ន្ធនឹងវិស័យជាសមត្ថកិច្ចរបស់គណៈកម្មការ ដូចជាការអនុវត្តច្បាប់ផ្លូវថ្នល់ ច្បាប់ចរាចរណ៍ផ្លូវគោក ការផ្គត់ផ្គង់ទឹកស្អាត និងការបែងចែកអគ្គិសនី ព្រមទាំងការលើកកម្ពស់សេវាសាធារណៈ និងភូមិ-ឃុំមានសុវត្ថិភាព នៅខេត្តព្រះសីហនុ<br>+ អញ្ជើញចុះបេសកកម្ម ដើម្បីសិក្សាស្វែងយល់អំពីការអនុវត្តច្បាប់អន្តោប្រវេសន៍ និងការផ្សព្វផ្សាយព័ត៌មាននៅខេត្តបាត់ដំបង និងខេត្តប៉ៃលិន<br>+ អញ្ជើញចុះបេសកកម្មស្វែងរកព័ត៌មាន | - ធ្វើលិខិតបេសកកម្មជូនសមាជិកព្រឹទ្ធសភា និងមន្ត្រីរាជការអមដំណើរសមាជិកព្រឹទ្ធសភា ចុះទៅសិក្សាស្វែងយល់អំពីការអនុវត្តច្បាប់ចំនួន២០នាក់ស្មើនឹង០៤ច្បាប់<br>- បានធ្វើកំណត់បង្ហាញលើព្រះរាជក្រម ព្រះរាជក្រឹត្យ អនុក្រឹត្យ ប្រកាស ដីកាអម សេចក្តីសម្រេច និងលិខិតផ្សេងៗចំនួន៦១ច្បាប់<br>- បានតាមដានព័ត៌មាន សិក្សាស្រាវជ្រាវ និងធ្វើតារាងសង្ខេបស្តីពីវឌ្ឍនភាពការងាររបស់ក្រសួងស្ថាប័ននានាចំនួន០៣ច្បាប់<br>- ផ្តល់សេវាផ្នែកថវិកានិងរថយន្ត សម្រាប់ក្រុមសមាជិកប្រចាំភូមិភាគទី៤ ចុះស្រាវជ្រាវព័ត៌មាន នៅខេត្តប៉ៃលិន ខេត្តបាត់ដំបង និងខេត្តបន្ទាយមានជ័យ<br>- ថត និងផ្សព្វផ្សាយព័ត៌មានសកម្មភាពរបស់សមាជិក-សមាជិកាព្រឹទ្ធសភា ក្នុងកិច្ចប្រជុំជួបពិភាក្សាការងារជាមួយអាជ្ញាធរអំពីការអនុវត្តច្បាប់ វឌ្ឍនភាពសំខាន់ៗ និងបញ្ហាប្រឈមនានា នៅខេត្តរតនគិរី ស្ទឹងត្រែង បន្ទាយមានជ័យ បាត់ដំបង និងខេត្តប៉ៃលិនចំនួន២៤លើក ។ |

| | |
|---|---|
| ទាក់ទងនឹងបញ្ហាប្រឈម និងសំណូមពររបស់ក្រុមប្រឹក្សាឃុំ-សង្កាត់នៅខេត្តបន្ទាយមានជ័យ និងខេត្តត្បូងឃ្មុំ ដើម្បីត្រៀមលក្ខណៈក្នុងការរៀបចំវេទិកានាពេលខាងមុខ<br>+អញ្ជើញចុះបំពេញបេសកកម្ម នៅខេត្តមណ្ឌលគិរី ខេត្តរតនគិរី ខេត្តស្ទឹងត្រែង និងខេត្តព្រៃវែង។ | |

**៤.មុខងារសហប្រតិបត្តិការអន្តរជាតិ និងទំនាក់ទំនងសាធារណៈ :**

| *របនាសម្ព័ន្ធនយោបាយ* | *របនាសម្ព័ន្ធរដ្ឋបាល* |
|---|---|
| - សម្តេចវិបុលសេនាភក្តី សាយឈុំ ប្រធានព្រឹទ្ធសភា អនុញ្ញាតឲ្យឯកអគ្គរដ្ឋទូតសាធារណរដ្ឋសិង្ហបុរី ឯកអគ្គរដ្ឋទូតសាធារណរដ្ឋប្រជាធិបតេយ្យទីម័រលេស្តេ ឯកអគ្គរាជទូតចក្រភពអង់គ្លេស ឯកអគ្គរាជទូតអៀរឡង់ខាងជើង និងអនុប្រធានសភាប្រឹក្សានយោបាយប្រជាជនចិន ចូលជួបសម្តែងការគួរសម និងសវនាការ<br>- សមាជិក-សមាជិកាព្រឹទ្ធសភា ជួបពិភាក្សាការងារ និងសម្តែងការគួរសមជាមួយឯកអគ្គរដ្ឋទូតសាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវ សមាជិកគណៈកម្មាធិការអចិន្ត្រៃយ៍នៃគណៈកម្មាធិការប្រឹក្សានយោបាយសាធារណរដ្ឋប្រជាមានិតចិន ប្រធានវិទ្យាស្ថានសភាកម្ពុជា (PIC) និងនាយិកាប្រតិបត្តិសម្ព័ន្ធ | - បានរៀបចំពិធីបដិសណ្ឋារកិច្ច ដំណើរទស្សនកិច្ចផ្លូវការរបស់គណៈប្រតិភូអន្តរជាតិ ឥស្សរជននយោបាយ អគ្គទូត និងអង្គការអន្តរជាតិនានា<br>- រៀបចំទីកន្លែងសម្រាប់ជំនួបសម្តែងការគួរសម និងបដិសណ្ឋារកិច្ចរវាងថ្នាក់ដឹកនាំព្រឹទ្ធសភា និងភ្ញៀវអន្តរជាតិចំនួន០៩លើក<br>- ថត និងផ្សព្វផ្សាយសកម្មភាពថ្នាក់ដឹកនាំ សមាជិកព្រឹទ្ធសភា ជួបភ្ញៀវជាតិ-អន្តរជាតិ ចំនួន២៤លើក<br>- រៀបចំតុបតែងលម្អទីកន្លែង ទង់ជាតិ វត្ថុអនុស្សាវរីយ៍ ចាត់ចែងអ្នកបកប្រែ ប្រព័ន្ធផ្សព្វផ្សាយ<br>- តុបតែងលម្អ ធ្វើផ្កាំងប៉ាណូ បដា ពាក្យស្លោក ក្នុងព្រះរាជពិធីបុណ្យចម្រើនព្រះជន្ម និងបុណ្យមាឃបូជាចំនួន០២លើក<br>- រៀបចំសម្អាតសាល ផ្គត់ផ្គង់ភេសជ្ជៈ សម្ភារអនាម័យ ក្នុងពិធីផ្សេងៗចំនួន១០លើក<br>- ទំនាក់ទំនងជាមួយស្ថានទូតបណ្តាប្រទេសជាមិត្ត |

| | |
|---|---|
| សត្វព្រៃ Wildlife Alliance<br>- សមាជិក-សមាជិកាព្រឹទ្ធសភា អញ្ជើញទៅបំពេញទស្សនកិច្ចសិក្សា និងផ្លាស់ប្តូរពិសោធន៍ការងារនៅប្រទេសប៊ែលហ្ស៊ិក ប្រទេសឥណ្ឌា និងចូលរួមជាកិត្តិយសក្នុងកិច្ចប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ទទួលបន្ទុកកិច្ចការសង្គម និងវប្បធម៌របស់តំបន់អាស៊ី នៅសាធារណរដ្ឋអ៊ីស្លាមអ៊ីរ៉ង់ ចូលរួមវគ្គបណ្តុះបណ្តាលស្តីពីអង្គការនិងពាណិជ្ជកម្មអន្តរជាតិពិភពលោកWTO នៅប្រទេសសិង្ហបុរី ។ | ដើម្បីសម្រួលបែបបទ និងកម្មវិធីទស្សនកិច្ច ធ្វើកំណត់បង្ហាញ កំណត់ហេតុ កំណត់ទូត និងជំនួយស្មារតី រៀបចំបែបបទបើកបន្ទប់ពិសេស (VIP) នៅអាកាសយានដ្ឋានអន្តរជាតិភ្នំពេញ ជូន-ទទួលដំណើរបេសកកម្មសរុបចំនួន៣៨លើក<br>- ចេញលិខិតបេសកកម្មជូនសមាជិកព្រឹទ្ធសភា និងមន្ត្រីរាជការចំនួន៣០នាក់ ស្មើនឹង១០ច្បាប់ និងបញ្ជូនលិខិតទៅក្រៅស្ថាប័នព្រឹទ្ធសភាចំនួន ៧៦ច្បាប់<br>- រៀបចំកញ្ចប់ដំណើរបេសកកម្មជូនថ្នាក់ដឹកនាំ និងសមាជិកព្រឹទ្ធសភា ទៅបំពេញបេសកកម្មក្រៅប្រទេសចំនួន០៥លើក<br>- ការពារសន្តិសុខ សុវត្ថិភាព រៀបចំសណ្តាប់ធ្នាប់ជូនថ្នាក់ដឹកនាំក្នុងកម្មវិធីផ្សេងៗ ដោយប្រើប្រាស់កម្លាំងសរុបចំនួន២៥នាក់ ស្មើនឹង០៤លើក<br>- អគ្គលេខាធិការ បានអនុញ្ញាតឲ្យគណៈប្រតិភូខុទ្ទកាល័យរដ្ឋសភាឡាវចូលជួបពិភាក្សាការងារ និងតំណាងភាគីក្រុមហ៊ុនចិន AFECC ចូលជួបពិភាក្សាការងារអំពីការសិក្សាប្លង់គម្រោងសាងសង់អគារសាលប្រជុំពេញអង្គព្រឹទ្ធសភា និងអនុប្រធានផ្នែកទំនាក់ទំនងសាធារណៈ អនុប្រធានផ្នែកព័ត៌មាន និងមន្ត្រីទទួលបន្ទុកផ្នែកសហប្រតិបត្តិការបច្ចេកទេសសភានៃសភាស្វីស ចូលជួបពិភាក្សាការងារ ដើម្បីស្វែងយល់ពីតម្រូវការក្នុងការពង្រឹងការងារប្រាស្រ័យទាក់ទងរបស់សភាកម្ពុជា ព្រមទាំងទៅបំពេញបេសកកម្មស្វែងរកជំនួយសម្រាប់អភិវឌ្ឍន៍ស្ថាប័នសភានៅសាធារណរដ្ឋបារាំង និងប្រទេសប៊ែលហ្ស៊ិក |

| | |
|---|---|
| | - ទំនាក់ទំនងជាមួយសកាំវ៉ូឡូនី ព្រុចសែល ប៊ែលហ្សិក ស្ថានទូតអូស្ត្រាលីប្រចាំប្រទេសវៀតណាម ទីភ្នាក់ងារអភិវឌ្ឍន៍បារាំង សមាគមអគ្គលេខាធិការ និយាយភាសាបារាំង សង្គមស៊ីវិល អាកាសចរណ៍ស៊ីវិល អគ្គស្នងការនគរបាលជាតិ និងក្រសួង-ស្ថាប័ននានា សម្រាប់ដំណើរទស្សនកិច្ច សិក្ខាសាលា និងបំពេញបេសកកម្មក្នុង-ក្រៅប្រទេស ស្នើសុំអាហារូបករណ៍ វគ្គបណ្តុះបណ្តាល និងការរៀបចំពិធីផ្សេងៗ ។ |

**៥.មុខងារអភិវឌ្ឍន៍ស្ថាប័ន** :

| របនាសម្ព័ន្ធនយោបាយ | របនាសម្ព័ន្ធរដ្ឋបាល |
|---|---|
| - ព្រឹទ្ធសភាកំពុងអនុវត្តការសាងសង់អគារខុទ្ទកាល័យថ្នាក់ដឹកនាំព្រឹទ្ធសភា ជាជំនួយពីរដ្ឋាភិបាលសាធារណរដ្ឋប្រជាមានិតចិន<br>- សិក្សាអំពីគម្រោងប្លង់កសាងអគារសាលប្រជុំថ្មី<br>- សហប្រតិបត្តិការជាមួយដៃគូរ ដើម្បីអភិវឌ្ឍធនធានមនុស្ស និងអភិវឌ្ឍស្ថាប័ន ។ | - ឯកឧត្តមអគ្គលេខាធិការព្រឹទ្ធសភា បានពិនិត្យផ្តល់យោបល់ និងចុះហត្ថលេខាលើឯកសារផ្សេងៗចំនួន៧២៣ច្បាប់<br>+ការងារគ្រប់គ្រងបុគ្គលិក:<br>- បានធ្វើលិខិតបទដ្ឋានផ្សេងៗពាក់ព័ន្ធនឹងការគ្រប់គ្រងមន្ត្រីរាជការសរុបចំនួន៤០ច្បាប់<br>- ប្រជុំគណៈកម្មការកែសម្រួលសេចក្តីព្រាងស្តីពីគោលការណ៍តែងតាំងមន្ត្រីរាជការឲ្យកាន់មុខតំណែង<br>- ប្រជុំក្រុមប្រឹក្សាវិន័យចំនួន០៣លើក អំពីករណីមន្ត្រីរាជការឈប់ឥតច្បាប់លើសកាលកំណត់<br>- ប្រជុំពិភាក្សាកំណត់លក្ខខណ្ឌនៃការវាយតម្លៃបន្តកិច្ចសន្យាសម្រាប់បុគ្គលិកជាប់កិច្ចសន្យា<br>- ប្រជុំស្តីពីបទបង្ហាញទិន្នន័យច្បាប់ព្រឹទ្ធសភា<br>- ប្រជុំជាមួយយន្តការអង្គការសង្គម ដើម្បីត្រួតពិនិត្យអំពីការអនុវត្តលក្ខន្តិកៈមន្ត្រីរាជការនៃក្រុមនីតិបញ្ញត្តិ<br>- គណៈកម្មការបន្តធ្វើបច្ចុប្បន្នភាពបទបញ្ជាផ្ទៃក្នុង |

| | |
|---|---|
| | អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា តាមស្មារតីអនុក្រឹត្យរបស់រាជរដ្ឋាភិបាល<br>- បានរៀបចំស្នើសុំគ្រឿងឥស្សរិយយសជូនមន្ត្រីរាជការដែលមានស្នាដៃសម្រាប់ឆ្នាំ២០១៥<br>+ការងារបណ្តុះបណ្តាលធនធានមនុស្ស:<br>- ការបណ្តុះបណ្តាលធនធានមនុស្សនៅក្នុង-ក្រៅប្រទេសសរុបចំនួន១៤វគ្គ មានសិក្ខាកាមចូលរួមចំនួន១៩៦នាក់ សិក្ខាសាលានៅក្រៅស្ថាប័នចំនួន០១លើក មានសិក្ខាកាមចូលរួមចំនួន០២នាក់<br>- កសាងផែនការបណ្តុះបណ្តាល និងអភិវឌ្ឍន៍ធនធានមនុស្សនៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភារយៈពេល០៥ឆ្នាំ (២០១៧-២០២១)<br>+ចាត់ចែងការងារកំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ:<br>- រៀបចំកសាងផែនការយុទ្ធសាស្ត្រថវិកា៣ឆ្នាំរំកិលព្រឹទ្ធសភា(២០១៧-២០១៩)<br>- រៀបចំថវិកាតាមកម្មវិធីឆ្នាំ២០១៦ និងការរៀបចំគម្រោងថវិកា ឆ្នាំ២០១៧<br>- ទូទាត់ថ្លៃទិញសម្ភារៈ គ្រឿងអេឡិចត្រូនិចចំនួន២៦លើក ថែទាំ និងជួសជុលសម្ភារឧបករណ៍បច្ចេកទេសផ្សេងៗចំនួន០៦លើក ជួសជុលកែលម្អសោភ័ណ្ឌភាពអគារសាលប្រជុំ ផ្លូវថ្នល់នៅក្នុងបរិវេណព្រឹទ្ធសភាចំនួន០៦លើក និងទូទាត់ការបោះពុម្ពសៀវភៅសរុបចំនួន៩០០ក្បាល ព្រមទាំងទូទាត់ថ្លៃអាហារសម្រន់ និងឯកសារផ្សេងៗចំនួន០៨លើក<br>- ទូទាត់ថ្លៃលទ្ធកម្មថ្លៃទិញប្រេងឥន្ធនៈ និងថ្លៃបោះពុម្ព |

| | |
|---|---|
| | ព្រឹត្តិបត្រប្រចាំខែមករា ឆ្នាំ២០១៦<br>- បានរៀបចំរបាយការណ៍ចំនួនមន្ត្រីក្របខ័ណ្ឌ និងមន្ត្រីមិនមែនក្របខ័ណ្ឌ របាយការណ៍ប្រាក់បៀវត្ស ប្រាក់បំណាច់ និងប្រាក់វិភាជន៍ផ្សេងៗ និងរបាយការណ៍ចំណាយថវិកាធៀបអាណត្តិប្រចាំខែឧសភាឆ្នាំ២០១៦ និងបានបញ្ជូនអាណត្តិប្រចាំត្រីមាសទី២ឆ្នាំ២០១៦ ផ្ញើជូនក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ<br>- រៀបចំសម្អាត តុបតែងសាល និងផ្តល់សេវាបម្រើភេសជ្ជៈ ផ្គត់ផ្គង់សម្ភារអនាម័យ ចំនួន១៥លើក មានអ្នកចូលរួមចំនួន៥៣០នាក់<br>- បានផ្គត់ផ្គង់សម្ភារអនាម័យ ការិយាល័យ និងភេសជ្ជៈ ចំនួន៦១សំណើ<br>- ថតចម្លងឯកសារបានចំនួន៥០សំណើ អស់ក្រដាសចំនួន១៥,៣៨៩សន្លឹក និងរៀបចំចងក្រងធ្វើជាសៀវភៅចំនួន០៥ក្បាល ព្រមទាំងផ្តល់សេវាដឹកជញ្ជូនក្នុងរាជធានីចំនួន៩៣នាក់ ស្មើនឹង៧៩លើក<br>**+ការកសាង និងជួសជុលហេដ្ឋារចនាសម្ព័ន្ធរូបវន្ត រឹង និងទន់:**<br>- បន្តតាមដាន សហការ និងត្រួតពិនិត្យដំណើរការការដ្ឋានសាងសង់អគារខុទ្ទកាល័យថ្នាក់ដឹកនាំព្រឹទ្ធសភា<br>- ចាត់ចែងការដ្ឋានចិន និងប្លង់អគារថ្មី<br>- ចាត់ចែងរៀបចំបន្ទប់ការិយាល័យជូនសមាជិកថ្មី<br>- រៀបចំទិន្នន័យ និងប្លង់: អគ្គិសនី លូទឹក ប្រព័ន្ធទឹកស្អាត អនុវត្តគម្រោងជុំវិញបណ្ណាល័យក្នុងបរិវេណអគារក្រហម ផ្លូវថ្នល់ អគារ សាលប្រជុំ |

| | |
|---|---|
| | ពេញអង្គ និងអនុវត្តគម្រោងជួសជុលបន្ទប់ទឹក<br>- ជួសជុល ខាត់ លាប និងបាំងបន្ទប់នៅហ្វ្រង់កូហ្វូនី អង្គភាពលទ្ធកម្ម ព្រមទាំងជួសជុល លាបខឿនថ្នល់ និងអ៊ុតគំនូសចរាចរឡើងវិញ<br>- តម្លើងធ្នើរដែកដាក់ឯកសារនៅនាយកដ្ឋានព័ត៌មាន និងតម្លើងរោងបណ្ដុះកូនឈើនៅនាយកដ្ឋានរដ្ឋបាល ព្រមទាំងតម្លើងម៉ាស៊ីនកាត់សៀវភៅ ដើម្បីសម្រួលដល់ការបញ្ចូល និងស្កេនឯកសារចូលក្នុងកម្មវិធី E-Library<br>- សហការចុះត្រួតពិនិត្យសត្វកណ្ដៀរ ដាក់សំណាញ់សត្វប្រចៀវនៅសាលប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ និងសាលប្រជុំពេញអង្គ<br>- ទិញកៅអីពូកដើងថ្មីដាក់នៅសាលបណ្ណាល័យ ចំនួន២០០គ្រឿង<br>- ជួសជុល និងផ្លាស់ប្តូរគ្រឿងអគ្គិសនី គ្រឿងអេឡិចត្រូនិច សោទ្វារ ទ្វារអូតូ ចំនួន៨១គ្រឿង បន្ទប់ទឹក និងបណ្ដាញទឹកចំនួន១២លើក<br>- សហការរៀបចំ និងប្រចាំការម៉ាស៊ីនភ្លើងនៅតាមសាលប្រជុំចំនួន១០លើក និងរៀបចំសណ្ដាប់ធ្នាប់រថយន្តគ្រប់ប្រភេទនៅក្នុងព្រឹទ្ធសភាចំនួន២១លើក<br>- រៀបចំដំណើរការប្រព័ន្ធព័ត៌មានវិទ្យា (ICT) ជាមួយក្រុមបច្ចេកទេសវៀតណាម<br>- ចុះត្រួតពិនិត្យ តាមដានប្រព័ន្ធNetwork, Internet, Connect Wifi និងជួសជុលម៉ាស៊ីនកុំព្យូទ័រ ដាក់កម្មវិធីកំចាត់មេរោគ Update Files Antivirus បញ្ចូលកម្មវិធីUnicode និងSet up កម្មវិធីសរុបចំនួន ៦១គ្រឿង ។ រៀបចំមាតិកា និង Upload រូបភាព |

| | |
|---|---|
| | សកម្មភាពការងារសំខាន់ៗរបស់ថ្នាក់ដឹកនាំព្រឹទ្ធសភា លើគេហទំព័រព្រឹទ្ធសភាសរុបចំនួន៧២ប្រធានបទ<br>+ការងារផ្សេងៗ:<br>- រៀបចំ និងចងក្រងសៀវភៅជាភាសាអង់គ្លេស ច្បាប់កាសែត ទស្សនាវដ្ដី ព្រឹត្តិបត្ររាជកិច្ចសរុប៧៥ក្បាល ដាក់លេខកូដសៀវភៅថ្មីចំនួន១៩៩ក្បាល ។ |

II.**ទិសដៅការងារខែមិថុនា ឆ្នាំ២០១៦**

**១.មុខងារនីតិកម្ម**:

-ត្រៀមរៀបចំប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ និងសម័យប្រជុំវិសាមញ្ញព្រឹទ្ធសភា

-សិក្សាច្បាប់ស្ដីពីការបោះឆ្នោតជ្រើសរើសសមាជិកព្រឹទ្ធសភា តាក់តែងក្រមសីលធម៌ និងបទបញ្ជាផ្ទៃក្នុងថ្មី ។

**២.មុខងារតំណាង** :

-ត្រៀមរៀបចំជូនថ្នាក់ដឹកនាំព្រឹទ្ធសភា ចូលរួមក្នុងពិធីផ្លូវការនានា នៅតាមបណ្ដាខេត្ត-ក្រុង

-ត្រៀមរៀបចំវេទិកាតាមភូមិភាគ សិក្ខាសាលា និងពិធីសំណេះសំណាលផ្លូវការផ្សេងៗ ។

**៣.មុខងារតាមដានការអនុវត្តច្បាប់ និងគោលនយោបាយ** :

-ត្រៀមសម្រួលការជួបសវនាការរវាងគណៈកម្មការជំនាញ និងក្រសួងស្ថាប័ននានា និងការចុះបេសកកម្មតាមបណ្ដាខេត្ត-ក្រុង ។

**៤.មុខងារសហប្រតិបត្តិការអន្តរជាតិ និងទំនាក់ទំនងសាធារណៈ**:

-ត្រៀមរៀបចំពិធីជំនួបរវាងថ្នាក់ដឹកនាំជាមួយគណៈប្រតិភូបរទេស និងអគ្គទូតនានា

-ត្រៀមរៀបចំបែបបទជូនថ្នាក់ដឹកនាំ និងសមាជិកព្រឹទ្ធសភា រួមទាំងអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា បំពេញបេសកកម្មក្រៅប្រទេស

-បន្តសកម្មភាពសហប្រតិបត្តិការការងារជាមួយដៃគូនានា៖ SES, CIM, KAS, GIZ, MARC PLAN FOUNDATION, UNESCO និងKOICA

-បន្តសហការជាមួយវិទ្យាស្ថានសភាកម្ពុជា អំពីជំហានរៀបចំការិយាល័យ PBO និងការពង្រីកឥទ្ធិពលតំបន់របស់វិទ្យាស្ថានសភាកម្ពុជាក្នុងក្របខណ្ឌសហប្រតិបត្តិការតំបន់ (ត្បូង-ត្បូង) និងការបង្កើតវិទ្យាស្ថានស្រាវជ្រាវសភាអាស៊ាន ។

**៥.មុខងារអភិវឌ្ឍន៍ស្ថាប័ន** :

-ការចាប់ផ្តើមរៀបចំប្រព័ន្ធ Website/Webpage ក្នុងកម្រិតអគ្គនាយកដ្ឋាន និងគណៈកម្មការ

-បង្កើនសមត្ថភាពស្រាវជ្រាវអំពីឯកសារបច្ចុប្បន្នភាពរបស់ជាតិ ដើម្បីបង្កើនសមត្ថភាពផ្តល់សេវាព័ត៌មានចាំបាច់

-បន្តកសាងប្រព័ន្ធគ្រប់គ្រងទិន្នន័យ តាមប្រព័ន្ធព័ត៌មានវិទ្យា កសាង Program និង Software ដើម្បីអនុវត្តតាមអង្គភាព និងការបណ្តុះបណ្តាល និងបានអនុវត្តកម្មវិធី E-បណ្ណាល័យ

-បន្តអភិវឌ្ឍន៍ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន កិច្ចសហប្រតិបត្តិការជាមួយវៀតណាម ចិន កូរ៉េ ជប៉ុន ឥណ្ឌា និងការបំពាក់សម្ភារបរិក្ខារជំនួយរបស់សាធារណរដ្ឋសង្គមនិយមវៀតណាម

-បន្តកសាងគោលការណ៍ គោលនយោបាយថ្មី ដើម្បីជាផលប្រយោជន៍ដល់ស្ថាប័ន និងមន្ត្រីរាជការ

-បន្តកសាងគោលការណ៍ណែនាំអំពីការរៀបចំដំណើរទស្សនកិច្ចសិក្សា និងកសាងខ្សែវីដេអូឯកសារ និងបោះពុម្ពឯកសារផ្សេងៗ

-ចាត់ចែងដំណើរការអង្គភាពនៃសវនកម្មបឋម អង្គភាពផលិតវីដេអូ អង្គភាពផលិតឯកសារផ្សព្វផ្សាយ

-ជំរុញការស្នើសុំអាហារូបករណ៍ និងដាក់ពាក្យប្រលងអាហារូបករណ៍តាមប្រកពពីកូរ៉េ ជប៉ុន ចិន អូស្ត្រាលី នូវែលសេឡង់ ឥណ្ឌា សិង្ហបុរី ម៉ាឡេស៊ី និងថៃ

-ការងារកំណែទម្រង់ហិរញ្ញវត្ថុសាធារណៈ និងការអនុវត្តជាក់ស្តែង

-ការរៀបចំថវិកាកម្មវិធីឆ្នាំ២០១៦ តាមអង្គភាពថវិកា និងចាប់ផ្តើមអនុវត្តការកត់ត្រាការចំណាយតាមអង្គភាពថវិកានីមួយៗ

-ការរៀបចំផែនការយុទ្ធសាស្ត្រថវិកា៣ឆ្នាំរំកិល និងការរៀបចំគម្រោងថវិកាឆ្នាំ២០១៧ ។

**III.សេចក្តីសន្និដ្ឋាន**

ក្នុងខែឧសភានេះ អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា បានចូលរួមអបអរព្រះរាជពិធីបុណ្យចម្រើនព្រះជន្ម ព្រះករុណាព្រះបាទ សម្តេចព្រះបរមនាថ នរោត្តម សីហមុនី ព្រមទាំងពិធីបុណ្យជាតិផ្សេងៗទៀត និងបានបំពេញការងារយ៉ាងសកម្មលើសេវាទ្រទ្រង់មុខងារនីតិកម្ម ប្រជុំពិនិត្យពិភាក្សាលើសេចក្តីព្រាងច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា ព្រមទាំងផ្តល់សេវាលើមុខងារផ្សេងៗទៀតជូនថ្នាក់ដឹកនាំ សមាជិក-សមាជិកាព្រឹទ្ធសភា បានដោយរលូន ។ ដោយឡែកលើមុខងារតំណាង បានចុះពិនិត្យព្យាបាលជំងឺជូនប្រជាពលរដ្ឋនៅខេត្តកំពង់ចាម កំពត តាកែវ ស្ទឹងត្រែង និងជួបសំណេះសំណាលជាមួយប្រជាពលរដ្ឋនៅខេត្តព្រៃវែង ស្វាយរៀង ត្បូងឃ្មុំ កណ្តាល បន្ទាយមានជ័យ រាជធានីភ្នំពេញ និងរៀបចំវេទិកានៅខេត្តកំពត និងខេត្តព្រះសីហនុ ។ ទន្ទឹមនេះ

លើមុខងារតាមដានការអនុវត្តច្បាប់ និងគោលនយោបាយ បានចុះសិក្សាស្វែងយល់អំពីការអនុវត្តច្បាប់ និងបញ្ហាប្រឈមនានា នៅខេត្តព្រះសីហនុ ប៉ៃលិន ត្បូងឃ្មុំ ព្រៃវែង និងចុះបំពេញបេសកកម្ម ខេត្តមណ្ឌលគិរី រតនគិរី ស្ទឹងត្រែង តាកែវ កណ្តាល និងរាជធានីភ្នំពេញ ។ ការអភិវឌ្ឍស្ថាប័ន បានបើកទំព័រថ្មីតាមការបញ្ចូលប្រើប្រាស់ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន ។ លើការងារកិច្ចសហប្រតិបត្តិការ អន្តរជាតិ មានថាមពលកាន់តែមមាញឹក បានបំពេញបេសកកម្មស្វែងរកជំនួយសម្រាប់អភិវឌ្ឍន៍ ស្ថាប័នសភានៅសាធារណរដ្ឋបារាំង និងប្រទេសប៊ែលហ្ស៊ិក ។ ទន្ទឹមនោះ កើតឡើងនូវកិច្ច សហប្រតិបត្តិការដ៏ល្អរវាងព្រឹទ្ធសភា និងរដ្ឋសភានៃសហគមន៍បារាំង Bruxelles-Wallonie។ ក្រៅពីនេះ មានការពិចារណាសិក្សាជាថ្មីចំពោះគម្រោងបូង់កសាងអគារសាលប្រជុំថ្មីដែលត្រូវធ្វើ បច្ចុប្បន្នភាព ។ ជាមួយគ្នានោះ បានពិចារណាអំពីការដ្ឋានផ្សេងទៀត ដែលត្រូវដំណើរការនាពេល ខាងមុខ ។

ភ្នំពេញ,ថ្ងៃទី០៧ ខែមិថុនា ឆ្នាំ២០១៦

**អគ្គលេខាធិការ**

អ៊ុំ_សារិទ្ធ